ជម្រើសសេវាកម្ម CFC

ជម្រើសទីមួយក្នុងសហគមន៍

អំពីសេវាកម្ម CFC

សេវាកម្មដែលបានរាយ គឺជាសេវាកម្មដែលបានផ្តល់ជូនក្រោម ជម្រើសទីមួយ ក្នុងសហគមន៍ (CFC) សម្រាប់អតិថិជនដែលមានសិទ្ធិទទួលបាន ។ មានការកម្រិតពីចំនួននៃសេវាកម្មនីមួយៗដែលអ្នកអាចជ្រើសរើស ។ មានមនុស្ស ជម្រើស និងធនធានជាច្រើន ដើម្បីជួយខណៈដែលអ្នកពិចារណាពីជម្រើសរបស់អ្នក ។

ការថែទាំផ្ទាល់ខ្លួន និងការផ្ទាស់វេនថែទាំ

សេវាកម្មថែទាំផ្ទាល់ខ្លួនផ្តល់ជំនួយជាមួយការកិច្ចប្រចាំថ្ងៃ ដូចជា ងូតទឹក ស្លៀកពាក់ ឬគ្រប់គ្រងថ្នាំរបស់អ្នក ។ បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ អ្នកជ្រើសរើសអ្នកផ្តល់សេវាកម្មដែលមានគុណសម្បត្តិគ្រប់គ្រាន់ និងទីតាំងដែលអ្នកចង់ទទួលការថែទាំរបស់អ្នក ។ ផ្អែកលើប្រាក់ចំណូលរបស់អ្នក DSHS ទឹងបង់ថ្លៃទាំងអស់ ឬផ្នែកខ្លះនៃសេវាកម្មទាំងនេះ ។ DSHS ក៏បង់ប្រាក់សម្រាប់ការបណ្តុះបណ្តាលអ្នកផ្តល់ការថែទាំមូលដ្ឋានសម្រាប់អ្នកផ្តល់ការថែទាំដែលមានគុណសម្បត្តិគ្រប់គ្រាន់ទាំងអស់ ។

នេះជាជម្រើសសម្រាប់ទីតាំងដែលអ្នកអាចទទួលសេវាកម្មថែទាំផ្ទាល់ខ្លួន ៖

- ✓ ផ្ទះរបស់អ្នក
- ✓ គេហដ្ឋានគ្រួសារមនុស្សពេញវ័យ
- ✓ កន្លែងជំនួយការរស់នៅ

របៀបគ្រប់គ្រងអ្នកផ្តល់ការថែទាំ និងជានិយោជក

អ្នកផ្តល់ការថែទាំរបស់អ្នកគឺជាផ្នែកដ៏សំខាន់នៃក្រុមថែទាំរបស់អ្នក ។ បើអ្នករស់នៅផ្ទះ ឬកំពុងគិតផ្ទាស់ទៅផ្ទះរបស់អ្នកផ្ទាល់ អ្នកនឹងត្រូវការគ្រប់គ្រងទម្លាប់ប្រចាំថ្ងៃនៃអ្នកផ្តល់ការថែទាំរបស់អ្នក ។ មានឧបករណ៍បណ្តុះបណ្តាលដែលពន្យល់ពីរបៀបជ្រើសរើស គ្រប់គ្រង និងបណ្តេញអ្នកផ្តល់ការថែទាំចេញ ។

ឯកសារទាំងនេះមានសម្រាប់អតិថិជនដែលស្នើសុំព័ត៌មានទាំងនេះ ។ សាកសួរអ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នក បើអ្នកចង់បានកូនសៀវភៅ វីដេអូបណ្តុះបណ្តាលដា DVD ឬតំណទៅវីដេអូបណ្តុះបណ្តាលលើគេហទំព័រ DSHS ។

ការផ្ទាស់វេនថែទាំ

ពេលអ្នករស់នៅក្នុងផ្ទះរបស់អ្នកផ្ទាល់ ការផ្ទាស់វេនថែទាំបង់ប្រាក់សម្រាប់អ្នកផ្តល់ការថែទាំជំនួយដើម្បីផ្តល់ការផ្ទាស់វេនរយៈពេលខ្លីសម្រាប់អ្នកផ្តល់ការថែទាំរបស់អ្នក ។ អ្នកផ្តល់ការថែទាំផ្ទាស់វេនអាចត្រូវបានប្រើដើម្បីផ្តល់ការសម្រាកដល់អ្នកផ្តល់ការថែទាំធម្មតារបស់អ្នក ឬដើម្បីជំនួស ប្រសិនបើអ្នកផ្តល់ការថែទាំធម្មតារបស់អ្នកឈឺ ឬមិនទំនេរ ។ អ្នកសម្រេចចំនួនម៉ោងដែលត្រូវបានផ្តល់សិទ្ធិរបស់អ្នកនឹងត្រូវបានប្រើសម្រាប់អ្នកផ្តល់ការថែទាំផ្ទាស់វេន ។

ការបណ្តុះបណ្តាលការទទួលបានជំនាញថ្មី

ការបណ្តុះបណ្តាលការទទួលបានជំនាញថ្មីផ្តល់ការបណ្តុះបណ្តាលបើអ្នកចង់បំពេញការកិច្ចកាន់តែឯករាជ្យ ។ អ្នកអាចចង់សិក្សាពីរបៀបរៀបចំអាហារ ឬបោកអ៊ុតសម្លៀកបំពាក់របស់អ្នក ។ ការបណ្តុះបណ្តាលលើការកិច្ចប្រចាំថ្ងៃគឺមាននៅក្នុងផ្ទះរបស់អ្នកឬក្នុងទីតាំងដែលការកិច្ចកើតឡើង ។

បច្ចេកវិទ្យាជំនួយ

ឧបករណ៍បច្ចេកវិទ្យាជំនួយអាចជួយអ្នកបំពេញការកិច្ចដោយគ្មានជំនួយពីអ្នកផ្សេង ឬជួយអ្នកឲ្យកាន់តែឯករាជ្យជាមួយការកិច្ចប្រចាំថ្ងៃ ។

ដើម្បីទទួលបានបច្ចេកវិទ្យាជំនួយ អ្នកគួរតែទាក់ទងគ្រូពេទ្យរបស់អ្នក និងស្នើសុំការបញ្ជូនសម្រាប់ការវាយតម្លៃដោយអ្នកព្យាបាល ។ អ្នកព្យាបាលនឹងផ្តល់យោបល់នូវបច្ចេកវិទ្យាត្រឹមត្រូវសម្រាប់អ្នក និងជួយអ្នកសិក្សាពីរបៀបប្រើវាពេលដែលអ្នកទទួលវា ។

ប្រព័ន្ធឆ្លើយតបបន្ទាន់ផ្ទាល់ខ្លួន (PERS)

PERS គឺជាឧបករណ៍អេឡិចត្រូនិចដែលភ្ជាប់ជាមួយទូរស័ព្ទរបស់អ្នកដែលអនុញ្ញាតឲ្យអ្នកទទួលជំនួយបន្ទាន់ ។ ពេលដែលដំណើរការ បុគ្គលិកនៅមជ្ឈមណ្ឌលឆ្លើយតបនឹងតាមដានការណែនាំដែលអ្នកបានផ្តល់ឲ្យដើម្បីទូរស័ព្ទរកជំនួយ ។

មានសេវាកម្មបច្ចេកវិទ្យាជំនួយ បើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់ដើម្បីមាន PERS របស់អ្នកដែលភ្ជាប់ជាមួយការតាមដានការដួល ឧបករណ៍កំណត់ទីតាំង ឬប្រព័ន្ធគ្រប់គ្រងថ្នាំ ។

មិនមែនទាំងអស់គ្នាមានសិទ្ធិទទួលបាន PERS ទេ ។ អ្នកគ្រប់គ្រងសំណុំរឿងរបស់អ្នកនឹងជួយអ្នកកំណត់ ថាតើអ្នកមានគុណសម្បត្តិគ្រប់គ្រាន់សម្រាប់ប្រព័ន្ធទាំងនេះឬទេ ។

សេវាកម្មការផ្ទាស់ប្តូរចូលសហគមន៍

សេវាកម្មការផ្ទាស់ប្តូរចូលសហគមន៍អាចជួយអ្នកផ្ទាស់ពីកន្លែងដែលទាំ ឬវិទ្យាស្ថានរដ្ឋចូលក្នុងសហគមន៍ ។ អ្នកអាចជ្រើសរើសផ្ទាស់ចូលផ្ទះរបស់អ្នកផ្ទាល់ ឬទៅគេហដ្ឋានគ្រួសារមនុស្សពេញវ័យ ឬកន្លែងជំនួយការរស់នៅ ។

Washington State Department of Social & Health Services

Transforming lives

DSHS-22-1616 CA (9/15)